# មាតិកា

ទំព័រ


- មាតិកា ........................................ i
- ឧទ្ទិសស្នាដៃ ........................................ iii
- សេចក្តីថ្លែងអំណរគុណ ........................................ iv
- អំណះអំណាង ........................................ v
- អក្សរកាត់ (ប្រើក្នុងនិក្ខេបបទនេះ) ........................................ vi
- មូលន័យសង្ខេប ........................................ vii
- Abstract ........................................ viii
- សង្ខេបនិក្ខេបបទ ........................................ ix
- Summary ........................................ xviii
- អារម្ភកថា ........................................ xxviii


## សេចក្តីផ្តើម


១- លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ ១

២- ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ ៤

៣- គោលបំណងនៃការស្រាវជ្រាវ ........................................ ៤

៤- ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ ........................................ ៥

៥- វិធីសាស្ត្រស្រាវជ្រាវ ........................................ ៥

៦- សារៈប្រយោជន៍នៃការស្រាវជ្រាវ ........................................ ៦

៧- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ ៧


## ជំពូកទី១
## ទស្សនៈទូទៅស្តីពីទំនាក់ទំនងអក្សរសិល្ប៍និងមនោគមវិជ្ជា


១.១- អក្សរសិល្ប៍និងសង្គមនយោបាយ ........................................ ៨

១.១.១- ទស្សនៈខ្លះៗចំពោះអក្សរសិល្ប៍ ........................................ ៨

១.១.២- ឥទ្ធិពលបដិការរវាងអក្សរសិល្ប៍និងសង្គមនយោបាយ ........................................ ១០

១.២- ទ្រឹស្តីទូទៅនៃមនោគមវិជ្ជា ........................................ ១២

១.២.១- ទស្សនៈខ្លះៗចំពោះមនោគមវិជ្ជា ........................................ ១២

១.២.២- ទស្សនៈសំខាន់ៗមួយចំនួនទាក់ទងនឹងមនោគមវិជ្ជាបដិវត្តន៍ ........................................ ១៣

១.៣- ទំនាក់ទំនងអក្សរសិល្ប៍និងមនោគមវិជ្ជា ........................................ ១៥

## ជំពូកទី២
## ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍កម្ពុជាប្រជាធិបតេយ្យ


២.១- ទិដ្ឋភាពទូទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ ........................................ ២៣

២.១.១- ចលនាតស៊ូរបស់អង្គការបដិវត្តន៍កុម្មុយនីស្តកម្ពុជាឆ្នាំ១៩៧០-១៩៧៥ ........................ ២៣

២.១.២- របបកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៥-១៩៧៩ ........................................ ២៥

២.១.៣- របបកម្ពុជាប្រជាធិបតេយ្យក្រោយឆ្នាំ១៩៧៩ ........................................ ២៦

២.២- ការវិវត្តនៃអក្សរសិល្ប៍កម្ពុជាប្រជាធិបតេយ្យ ........................................ ២៨

២.២.១- អ្នកនិពន្ធនិងការផ្សព្វផ្សាយស្នាដៃអក្សរសិល្ប៍-សិល្បៈ ........................................ ៣១

២.២.២- ទិដ្ឋភាពទូទៅនៃការវិវត្តអក្សរសិល្ប៍-សិល្បៈពីឆ្នាំ១៩៧០-១៩៧៩ ........................ ៣៧

២.៣- មនោគមវិជ្ជានៃអក្សរសិល្ប៍-សិល្បៈកម្ពុជាប្រជាធិបតេយ្យ ........................................ ៩៣

២.៣.១- ការអប់រំមនោគមវិជ្ជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ........................................ ៩៣

២.៣.២- ខ្លឹមសារមនោគមវិជ្ជាតាមរយៈស្នាដៃអក្សរសិល្ប៍-សិល្បៈមួយចំនួន ........................ ៩៩


## ជំពូកទី៣
## ឥទ្ធិពលបដិការនៃមនោគមវិជ្ជាអក្សរសិល្ប៍-សិល្បៈ
## ក្នុងសង្គមកម្ពុជាប្រជាធិបតេយ្យ


៣.១- ឥទ្ធិពលនិងលក្ខណៈមនោគមវិជ្ជានៃរបបកម្ពុជាប្រជាធិបតេយ្យ ........................................ ១៣៣

៣.១.១- ឥទ្ធិពលនៃមនោគមវិជ្ជានៃរបបកម្ពុជាប្រជាធិបតេយ្យ ........................................ ១៣៣

៣.១.២- លក្ខណៈនៃមនោគមវិជ្ជានៃរបបកម្ពុជាប្រជាធិបតេយ្យ ........................................ ១៤០

៣.២- ឥទ្ធិពលមនោគមវិជ្ជានៃអក្សរសិល្ប៍-សិល្បៈក្នុងសង្គមកម្ពុជាប្រជាធិបតេយ្យ ........................ ១៤៧

៣.២.១- ឥទ្ធិពលមនោគមវិជ្ជានៃអក្សរសិល្ប៍-សិល្បៈមកលើការដឹកនាំប្រទេសរបស់
បក្សកុម្មុយនីស្តកម្ពុជា ........................................ ១៥០

៣.២.២- ឥទ្ធិពលមនោគមវិជ្ជានៃអក្សរសិល្ប៍-សិល្បៈមកលើការរស់នៅរបស់ប្រជាជន ........................ ១៦៧

៣.៣- ផលវិបាកនៃឥទ្ធិពលមនោគមវិជ្ជាក្នុងសង្គមកម្ពុជាប្រជាធិបតេយ្យ ........................................ ១៧១

៣.៣ ១- ផលវិបាកនៃឥទ្ធិពលមនោគមវិជ្ជាមកលើសង្គមកម្ពុជា ........................................ ១៧២

៣.៣.២- ការបរាជ័យនៃមនោគមវិជ្ជាក្នុងសង្គមកម្ពុជាប្រជាធិបតេយ្យ ........................................ ១៨៤

**សេចក្តីសន្និដ្ឋាន** ........................................ ១៩០

**គន្ថនិទ្ទេស** ........................................ ១៩៤

**ឧបសម្ព័ន្ធ** ........................................ ២០០

# ឧទ្ទិសស្នាដៃ

## សូមឧទ្ទិសស្នាដៃនេះថ្វាយ និង ជូនចំពោះ

ព្រះវិញ្ញាណក្ខន្ធ ព្រះវីរក្សត្រខ្មែរគ្រប់ជំនាន់

វិញ្ញាណក្ខន្ធ បុព្វការីជន អ្នកប្រាជ្ញ កវី បណ្ឌិត វីរជនស្នេហាជាតិខ្មែរគ្រប់ជំនាន់ ដែលបានបូជាកម្លាំងកាយ កម្លាំងចិត្ត និង ធ្វើពលីកម្មគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុយុត្តិធម៌ សិទ្ធិសេរីភាព សន្តិភាព និងបូរណភាពទឹកដី ពិសេស អ្នកស្នេហាអក្សរសាស្ត្រជាតិ ដែលរួមចំណែកធ្វើឱ្យអត្តសញ្ញាណជាតិខ្មែរបានគង់វង្សនិងរីកចម្រើនរហូតដល់សព្វថ្ងៃ។

វិញ្ញាណក្ខន្ធ ញាតិមិត្ត ជនរួមជាតិខ្មែរ ក៏ដូចជាជនបរទេសទាំងឡាយ ដែលបានស្លាប់យ៉ាងអយុត្តិធម៌ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រយៈពេល៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ ក្រោមការដឹកនាំរបស់ ប៉ុល ពត។

សូមឱ្យពលីកម្មនេះ ប្រែក្លាយទៅជាមនសិការស្នេហាជាតិដ៏រឹងមាំ មោះមុតសម្រាប់មនុស្សសម័យថ្មី រួមរស់នៅជាមួយគ្នាប្រកបទៅដោយភាពយោគយល់គ្នា ភាតរភាព និង សាមគ្គីភាពក្នុងស្មារតី «អ្វីៗដើម្បីអភិវឌ្ឍជាតិ មាតុភូមិជាទីស្នេហារបស់យើង»។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

លោកឪពុក **ព្រាប ណុន** អ្នកម្តាយ **ឃុន ម៉ើ** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅនិងផ្តល់ឱកាសឱ្យកូនបានរៀនសូត្រ ព្រមទាំងក្រុមគ្រួសារទាំងអស់តែងតែជួយលើកទឹកចិត្តដល់រូបខ្ញុំក្នុងការសិក្សារហូតបានដល់ទីបញ្ចប់ដូចបំណងប្រាថ្នាពេលនេះ។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានគាំទ្រគ្រប់បែបយ៉ាងក្នុងការបង្កើតស្ថាប័នរាជបណ្ឌិត្យសភាកម្ពុជា ដើម្បីដំណើរការបណ្តុះបណ្តាលបញ្ញាញាណជាន់ខ្ពស់ ដែលជាធនាគារខួរក្បាលរបស់ជាតិក្នុងការស្រាវជ្រាវ។

ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ជានិច្ចកាល ឯកឧត្តមតែងតែលើកទឹកចិត្ត ផ្តល់អនុសាសន៍ល្អៗដល់និស្សិតនៃវគ្គសិក្សាជាន់ខ្ពស់នៅរាជបណ្ឌិត្យសភាកម្ពុជា ចាប់តាំងពីការសិក្សានៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ រហូតដល់ថ្នាក់បណ្ឌិតនេះ ដើម្បីឱ្យការស្រាវជ្រាវរបស់ខ្លួនសម្រេចបានជោគជ័យល្អ។

បណ្ឌិតសភាចារ្យ **ស៊ិន សំណាង** អតីតប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដែលលោកបានរៀបចំបង្កើតឱ្យមានការបណ្តុះបណ្តាល រួមទាំងប្រមែប្រមូលបញ្ញវន្តជាតិ អន្តរជាតិឱ្យចូលរួមក្នុងការផ្តល់ពុទ្ធិល្អៗដល់វគ្គសិក្សានៃយើងខ្ញុំ។

បណ្ឌិតសភាចារ្យ **ខ្លួត ធីតា** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដែលលោកជំទាវបានពង្រឹងនិងបន្តនិរន្តរភាពនៃការបណ្តុះបណ្តាលនេះឱ្យកាន់តែមានប្រសិទ្ធភាពឡើង ក៏ដូចជាការបង្កលក្ខណៈល្អៗសម្រាប់វគ្គសិក្សានៃយើងខ្ញុំ។

បណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន** អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា នាយកមជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសាស្ត្រាចារ្យណែនាំដែលបានចំណាយពេលវេលាដ៏មានតម្លៃជួយជ្រោមជ្រែងទាំងកម្លាំងកាយ កម្លាំងចិត្ត ផ្តល់គំនិតល្អៗដល់ខ្ញុំបាទ ដើម្បីធ្វើឱ្យការស្រាវជ្រាវនិងការសរសេរនិក្ខេបបទនេះមានលក្ខណៈវិទ្យាសាស្ត្រ និង ទទួលបានជោគជ័យជាស្ថាពរ។

បណ្ឌិតសភាចារ្យ **សោម សុមុនី** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ វិទ្យាសាស្ត្រសង្គម ជាសាស្ត្រាចារ្យណែនាំរងដែលជានិច្ចកាលតែងផ្តល់នូវគំនិតល្អៗនិងបានបង្ហាញពីរបៀបសរសេរនិក្ខេបបទ របៀបស្រាវជ្រាវ ដើម្បីឱ្យការសរសេរនិក្ខេបបទបានចប់ទាន់ពេល និង ទទួលជោគជ័យ។

បណ្ឌិត **នៅ ស៊ុន** បណ្ឌិត **ម៉ៅ សុភ្ភន** បណ្ឌិត **ស៊ុន សូត** បណ្ឌិត **ឆេង វណ្ណារិទ្ធ** និង លោក លោកស្រី សាស្ត្រាចារ្យបណ្ឌិត ជាសាស្ត្រាចារ្យបង្រៀនដែលបានផ្តល់ចំណេះដឹងថ្មីៗឱ្យខ្ញុំបាទក្នុងការសិក្សាស្រាវជ្រាវក៏ដូចការសរសេរនិក្ខេបបទនេះ។

លោក **ឆាំង យុ** នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានអនុញ្ញាតឱ្យខ្ញុំបាទបានស្រាវជ្រាវឯកសារនៅមជ្ឈមណ្ឌលឯកសាររបស់លោក ព្រមទាំងមន្ត្រីនៃមជ្ឈមណ្ឌលឯកសារទាំងអស់ ដែលបានជួយផ្តល់ជាគំនិតយោបល់ល្អៗដល់ខ្ញុំបាទក្នុងការស្រាវជ្រាវលើឯកសារផ្សេងៗ ដោយផ្ទាល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជានិងឯកសារចាំបាច់យ៉ាងច្រើនទៀតក្នុងការសរសេរស្នាដៃនេះឡើង។

សូម សម្តេច ឯកឧត្តមបណ្ឌិតសភាចារ្យ សាស្ត្រាចារ្យ បណ្ឌិត លោក លោកស្រី ទាំងអស់ជួបប្រទះតែនឹងសេចក្តីសុខ សុភមង្គល និង ជោគជ័យក្នុងជីវិតគ្រប់ពេលវេលា។

# អំណះអំណាង

ខ្ញុំបាទ **ណុន សុខា** សូមធានាអះអាង និង ទទួលខុសត្រូវចំពោះខ្លឹមសារនិក្ខេបបទដែលមានចំណងជើងថា *ឥទ្ធិពលមនោគមវិជ្ជានៃអក្សរសិល្ប៍កម្ពុជាប្រជាធិបតេយ្យ* ពិតជាស្នាដៃសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទ ក្រោមការណែនាំផ្ទាល់របស់បណ្ឌិតសភាចារ្យ **ស៊ំ ឈុំប៊ុន**។ លទ្ធផលនៃការសិក្សាស្រាវជ្រាវដែលមាននៅក្នុងនិក្ខេបបទនេះ ពិតជាកើតចេញពីការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវតាក់តែងនិពន្ធ វិភាគ និង ចងក្រងបានជាស្នាដៃដោយពុំមានចម្លងចេញពីនិក្ខេបបទរបស់អ្នកដទៃណាមួយឡើយ។ ខ្លឹមសារនៃនិក្ខេបបទនេះ ខ្ញុំបានប្រើប្រាស់ទិន្នន័យ ព័ត៌មាន ដែលប្រមូលបានពីឯកសារពាក់ព័ន្ធនានានិងតាមរយៈការសម្ភាសជាមួយ ឥស្សរជន ប្រជាជន ដែលនៅចងចាំព្រឹត្តិការណ៍ពាក់ព័ន្ធទាំងឡាយ ជាពិសេស សម្ភាសជាមួយអតីតកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមជាមួយនឹងបទពិសោធន៍ និង ចំណេះរបស់ខ្លួនបាទខ្ញុំផ្ទាល់។

រាជធានីភ្នំពេញ ថ្ងៃចន្ទ ទី ៥ ខែ តុលា ឆ្នាំ២០១៥

ហត្ថលេខា

**ណុន សុខា**

រាជធានីភ្នំពេញ ថ្ងៃចន្ទ ទី ៥ ខែ តុលា ឆ្នាំ២០១៥

បានឃើញនិងឯកភាព

**សាស្ត្រាចារ្យណែនាំ**

បណ្ឌិតសភាចារ្យ **ស៊ំ ឈុំប៊ុន**

# អក្សរកាត់

(ប្រើក្នុងនិក្ខេបបទនេះ)

| | |
|---|---|
| - -ដ- | ដដែល |
| - ដ.ឯ.ម. | ដូចឯកសារមុន |
| - ស. យុកែក | សម្ព័ន្ធយុជនកុម្មុយនីស្តកម្ពុជា |
| - រ. រ. ជ. ក. | រណសិរ្សរួបរួមជាតិកម្ពុជា |
| - C. I. A. | Central Intelligence Agency. |
| - K. G. B. (К. Г. Б.) | Komitet Gossoudarstvennoï Bezopasnosti. |
| | " Comité pour la Sécurité d'État" |

# មូលន័យសង្ខេប

អក្សរសិល្ប៍-សិល្បៈនៃរបបកម្ពុជាប្រជាធិបតេយ្យជារបត់ថ្មីមួយនៃប្រវត្តិអក្សរសិល្ប៍ខ្មែរ។ អ្នកខ្លះយល់ថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យគ្មានអក្សរសិល្ប៍ទេ។ តាមការសិក្សាស្រាវជ្រាវ យើងឃើញថា ក្នុងរបបនេះពិតជាមានអក្សរសិល្ប៍ ដែលស្នាដៃទាំងនោះមានដូចជា កំណាព្យ ចម្រៀង ពាក្យស្លោក កម្រងរឿង ជាដើម និង មានខ្លឹមសារបម្រើឱ្យបដិវត្តន៍ថែមទៀតផង។ អក្សរសិល្ប៍-សិល្បៈបដិវត្តន៍មានតែបទចម្រៀងទេដែលមានភាពលេចធ្លោជាងគេក្នុងការផ្សព្វផ្សាយ ដែលចម្រៀងទាំងនោះត្រូវបានផ្សព្វផ្សាយមិនឈប់ឈរនៅតាមការដ្ឋាននានា ដើម្បីឃោសនាអំពីគោលមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

យើងក៏ឃើញថា អក្សរសិល្ប៍-សិល្បៈនៃរបបកម្ពុជាប្រជាធិបតេយ្យមានខ្លឹមសារប្រែប្រួលទៅតាមដំណាក់កាលប្រវត្តិសង្គមនៃរបបនេះផងដែរ។ ក្នុងដំណាក់កាលនៃការតស៊ូរបស់ពួកខ្មែរក្រហម អក្សរសិល្ប៍-សិល្បៈ ពិសេស បទចម្រៀងបដិវត្តន៍មានខ្លឹមសារបង្រួបបង្រួម ប្រមូលកម្លាំងប្រជាជនគ្រប់ស្រទាប់វណ្ណៈគ្រប់សមាសភាពឱ្យចូលរួមក្នុងចលនាតស៊ូដើម្បីយកឈ្នះសង្គ្រាមជាមួយរបបសាធារណរដ្ឋខ្មែរ។ ក្នុងដំណាក់កាលនេះ អក្សរសិល្ប៍-សិល្បៈមានចរិតផ្តួលរំលំ អត្ថន័យរបស់វាបានលើទឹកចិត្តប្រជាជនឱ្យចូលរួមតស៊ូ និង អប់រំប្រជាជនក្រីក្រ កម្មករ កសិករ ឱ្យមានការឈឺចាប់ ឱ្យស្អប់ខ្ពើមពួកមូលធន និង ភាពអយុត្តិធម៌សង្គម។ ក្រោយថ្ងៃជ័យជម្នះ១៧ មេសា ១៩៧៥ យើងឃើញថា អក្សរសិល្ប៍-សិល្បៈមានខ្លឹមសារលើកយកផែនការបង្កបង្កើនផល ចលនាការពារកសាងប្រទេស ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីធ្វើបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយមនៅកម្ពុជាមកបរិយាយ។ ក្រោយការប្រកាសជាចំហនូវការប្តូរនៃថ្ងៃកំណើតបក្សកុម្មុយនីស្ត កម្ពុជានិងតួនាទីជាមគ្គុទ្ទេសក៍បក្សរបស់ ប៉ុល ពត នាខែកញ្ញា ឆ្នាំ១៩៧៧មក អក្សរសិល្ប៍-សិល្បៈនៅតែមានភារកិច្ចបម្រើមាគ៌ាសង្គមនិយមផ្ទិនផ្ទៅរបស់បក្សកុម្មុយនីស្តកម្ពុជាដដែល។ អង្គការនៅតែប្រើអក្សរសិល្ប៍-សិល្បៈជារណសិរ្សសតិអារម្មណ៍នយោបាយក្នុងការអនុវត្តមាគ៌ា«មហាលោតផ្លោះ មហាអស្ចារ្យ»។ ពាក្យពេចន៍នៃអត្ថបទកំណាព្យ-ចម្រៀងសុទ្ធតែបានណែនាំយុវជន-យុវនារីឱ្យដើរតាមនយោបាយបក្សដោយឥតងាករេ។ ក្រៅពីខ្លឹមសារខាងលើនេះ ស្នាដៃកំណាព្យ-ចម្រៀងបដិវត្តន៍ក៏លើកឡើងពីការកម្ទេចនូវរាល់ជាតុមិនបដិវត្តន៍ កម្ទេចនូវរាល់ខ្មាំងបដិវត្តន៍ថែមទៀតផង។

ជារួមរួម យើងឃើញថា អក្សរសិល្ប៍-សិល្បៈនៃរបបកម្ពុជាប្រជាធិបតេយ្យមានខ្លឹមសារសំខាន់គឺបម្រើឱ្យមនោគមវិជ្ជាបដិវត្តន៍ទាំងស្រុង ដែលមនោគមវិជ្ជាទាំងនោះមានឥទ្ធិពលយ៉ាងខ្លាំងក្លាមកលើការដឹកនាំនិងការរស់នៅរបស់ប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មនោគមវិជ្ជាមានលក្ខណៈដាច់ខាត មោះមុត មិនរុញរា ឯករាជ្យ ម្ចាស់ការ ជាដើម ដែលមានក្នុងអត្ថបទអក្សរសិល្ប៍-សិល្បៈបដិវត្តន៍ទាំងនោះ បានលេចឡើងយ៉ាងច្បាស់ក្នុងចរិតដឹកនាំនៃកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យដែលមានលក្ខណៈកាចសាហាវ ឃោរឃៅ ផ្តាច់ការ ចំពោះប្រជាជន។ ឥទ្ធិពលនេះក៏បានធ្វើឱ្យការរស់នៅរបស់ប្រជាជនផ្លាស់ប្តូរខុសពីទំនៀមទម្លាប់ដើមទាំងស្រុងដែរ។ ប្រជាជនត្រូវរស់នៅសមូហភាព ធ្វើការងាររួម ហូបបាយរួម ដេករួម។ ជាងនេះទៅទៀត ឥទ្ធិពលនេះបានធ្វើឱ្យសង្គមមានអំពើសងសឹកគ្នា មានការរើសអើងគ្នារវាងប្រជាជននៅតាមតំបន់រំដោះនិងប្រជាជនដែលត្រូវអង្គការជម្លៀសពីទីក្រុងនានា ពិសេស ធ្វើឱ្យការរស់នៅរបស់ប្រជាជនមានភាពភ័យខ្លាចជានិច្ច។

សរុបមក អក្សរសិល្ប៍-សិល្បៈនៃរបបកម្ពុជាប្រជាធិបតេយ្យ មានខ្លឹមសារបម្រើតែមនោគមវិជ្ជាបក្សកុម្មុយនីស្តកម្ពុជាមួយមុខប៉ុណ្ណោះ។

# Abstract

Literature of the Democratic Kampuchea is a new form of Khmer historical literature. Someone has thought the Democratic Kampuchea regime had no literature. Based on the study, we see that in this regime there are literature works such as poetry, songs, slogans, stories, etc. and all of these are the revolutionary ones. Among of these works only the revolutionary songs are stood out in the media and those songs were sung endless from day to day to propagandize the policy guidelines of the Communist Party of Kampuchea.

The meanings of Literature of Democratic Kampuchea were changing follow to the stage of historical social of this regime. The Literature in the struggle stage of Khmer Rouge, especially, the meaning of revolutionary songs called for people to join together fighting with the Khmer Republic regime. Moreover, it had encouraged and educated the poor people to hate and feel nauseated to capitalist and social injustice. After the Victory day in 1975, the literature played a role in bringing message of Angkar's plan to the population for growing rice and nation defending in order construct the revolution in Cambodia toward Socialism. After the declaring of the Communist Party of Kampuchea in September 1977, the literature works still were used to serve policy guideline of the Communist Party of Kampuchea. Angkar used literature as the front political mental instrument to implement their politics of Great Leap and Marvel. The wording of poem and songs are used to introduce the youth to follow the Angkar's advice. Besides the above content it also admonished people to destroy all items anti-revolution and all enemies of revolution.

Overall, we see that the meaning of literature of Democratic Kampuchea had propagandizes the revolutionary ideology of Angkar and it had influenced the leadership and the lives of the people in the Democratic Kampuchea regime. The revolutionary ideology such as to be absolute, dedicated, and not to hesitate to be independent, etc. were appeared clearly in the leadership characteristics of Kampuchea leaders that made one see they were vicious, cruel, and absolute. These had affected to the living of people such as in collective living, collective working and eating, including sleep. Moreover, they had brought about social revenge and discriminate between people in the liberated zone and the people who were evacuated from other cities, especially, made people fear all time.

To sum up, the literature of the Democratic Kampuchea contains the unique ideological meaning of Communist Party of Kampuchea.